**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស**

លេខៈ ០៩៤/១៧ សសរ

# សេចក្ដីសម្រេច
# ស្ដីពី
# ការបង្កើតក្រុមការងារវាយតម្លៃផ្ដល់ចំណាត់ថ្នាក់ប្រចាំឆ្នាំ ជូនគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

## គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៨០៨ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- បានឃើញអនុក្រឹត្យលេខ ២៧៣ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- បានឃើញសេចក្ដីសម្រេចលេខ ០០២/១៤ សសរ ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤ ស្ដីពីការបង្កើតក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន សម្រាប់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- បានឃើញសេចក្ដីសម្រេចលេខ ០០១/១៤ សសរ ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ
- យោងតាមការចាំបាច់

## <u>សម្រេច</u>

### ប្រការ ១ ៖

ត្រូវបានបង្កើតក្រុមការងារវាយតម្លៃផ្ដល់ចំណាត់ថ្នាក់ប្រចាំឆ្នាំ ជូនគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១. លោកជំទាវ | ជូ ប៊ុនអេង | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ | ប្រធាន |
| ២. លោកជំទាវ | ស៊ើង សរសុចិត្តា | រដ្ឋលេខាធិការក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងជាអនុប្រធានក្រុមការងារទេសន្តរប្រវេសន៍ | អនុប្រធាន |
| ៣. ឯកឧត្តម | ជិន ម៉ាលិន | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៤. ឯកឧត្តម ឧត្តមសេនីយ៍ឯក | ថោង សំអាត | អគ្គលេខាធិការ គ.ជ.ប.ជ | អនុប្រធាន |
| ៥. ឯកឧត្តម | ប៉ែន ពេជ្រសាលី | អគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ នៃក្រសួងយុត្តិធម៌ | សមាជិក |
| ៦. ឯកឧត្តម ឧត្តមសេនីយ៍ឯក | យ៉ែម ច័ន្ទណារុំ | អគ្គលេខាធិការរង គ.ជ.ប.ជ | សមាជិក |
| ៧. ឯកឧត្តម ឧត្តមសេនីយ៍ឯក | យឹម វិរៈ | អគ្គលេខាធិការរង គ.ជ.ប.ជ | សមាជិក |
| ៨. ឯកឧត្តម ឧត្តមសេនីយ៍ឯក | ខៀវ ចាន់រ៉ា | អគ្គលេខាធិការរង គ.ជ.ប.ជ | សមាជិក |

| | | | |
|---|---|---|---|
| ៩. លោកជំទាវ ឧត្តមសេនីយ៍ឯក | ប៉ុណ្ណ សំខាន់ | អគ្គលេខាធិការរង គ.ជ.ប.ជ | សមាជិកា |
| ១០. ឯកឧត្តម ឧត្តមសេនីយ៍ឯក | ស៊ុន រ៉ូ | អគ្គលេខាធិការរង គ.ជ.ប.ជ | សមាជិក |
| ១១. លោកជំទាវ | រ៉ន ស៊ីរីលក្ខិណា | អគ្គលេខាធិការរង គ.ជ.ប.ជ | សមាជិកា |
| ១២. ឯកឧត្តម ឧត្តមសេនីយ៍ទោ | អ៊ូ ម៉ានីរ៉ា | អគ្គលេខាធិការរង គ.ជ.ប.ជ | សមាជិក |
| ១៣. លោក | ស៊ិន សេងហុក | ប្រធាននាយកដ្ឋាន នីតិកម្ម នៃក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៤. លោកស្រី | ព្រុំ សុខន | ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិកា |
| ១៥. លោកឧត្តមសេនីយ៍ទោ | ប៉ាក់ យូលាង | អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ១៦. លោក | ជីន ចន | អនុប្រធាននាយកដ្ឋានការពារផ្លូវច្បាប់ នៃក្រសួងកិច្ចការនារី | សមាជិក |

ក្រុមការងារខាងលើនេះ មានភារកិច្ចដូចខាងក្រោម ៖

- ធ្វើការណែនាំដល់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ អំពីការវាយតម្លៃ និងធ្វើចំណាត់ថ្នាក់នៃលទ្ធផល សកម្មភាពរបស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ
- បង្កើតទម្រង់/ ឬ រៀបចំកម្រងសំណួរលក្ខណៈវិនិច្ឆ័យសម្រាប់ធ្វើការវាយតម្លៃ
- ធ្វើរបាយការណ៍លទ្ធផល នៃការវាយតម្លៃ បែងចែកចំណាត់ថ្នាក់ និងស្នើសុំការពិនិត្យសម្រេចពី **សម្តេចក្រឡាហោម** ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- ចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធានក្រុមការងារវាយតម្លៃ
- អនុវត្តការងារផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងការវាយតម្លៃតាមការចាត់តាំងរបស់ប្រធានក្រុមការងារវាយតម្លៃផ្តល់ចំណាត់ថ្នាក់ប្រចាំឆ្នាំ។

**ប្រការ ២ ៖**

ត្រូវបានបង្កើតក្រុមជំនួយការជួយក្រុមការងារវាយតម្លៃផ្តល់ចំណាត់ថ្នាក់ប្រចាំឆ្នាំ ជូនគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១. ឯកឧត្តម ឧត្តមសេនីយ៍ឯក | យ៉ែម ច័ន្ទណារ៉ុ | អគ្គលេខាធិការរង គ.ជ.ប.ជ | ប្រធាន |
| ២. លោកឧត្តមសេនីយ៍ទោ | គង់ ពុទ្ធី | ប្រធានលេខាធិការដ្ឋាន គ.ជ.ប.ជ | អនុប្រធាន |
| ៣. លោក | ឆេង វណ្ណា | អនុប្រធានលេខាធិការដ្ឋាន គ.ជ.ប.ជ | សមាជិក |
| ៤. លោក | ប៉ុណ្ណ ចន្ថា | អនុប្រធានលេខាធិការដ្ឋាន គ.ជ.ប.ជ | សមាជិក |
| ៥. លោកវរសេនីយ៍ឯក | ថោង រទ្ធី | អនុប្រធានលេខាធិការដ្ឋាន គ.ជ.ប.ជ | សមាជិក |
| ៦. លោកវរសេនីយ៍ឯក | ហាង ជីវ័ន្ត | អនុប្រធានលេខាធិការដ្ឋាន គ.ជ.ប.ជ | សមាជិក |
| ៧. លោកវរសេនីយ៍ឯក | រ៉ន សុភ័ក្ត្រវឌ្ឍនា | អនុប្រធានលេខាធិការដ្ឋាន គ.ជ.ប.ជ | សមាជិក |
| ៨. លោកវរសេនីយ៍ទោ | អ៊ុំ ធារ៉ែន | នាយការិយាល័យ | សមាជិក |
| ៩. លោកវរសេនីយ៍ត្រី | អ៊ុន សុខជា | នាយការិយាល័យ | សមាជិក |
| ១០. លោក | អ៊ឹង ហាក់លៀង | នាយការិយាល័យ | សមាជិក |
| ១១. លោក | អ៊ុំ ភាមិន្ទ | នាយការិយាល័យ | សមាជិក |
| ១២. លោកវរសេនីយ៍ត្រី | ឯម សុជាតិ | នាយការិយាល័យ | សមាជិក |

ក្រុមជំនួយការជួយក្រុមការងារវាយតម្លៃផ្តល់ចំណាត់ថ្នាក់ប្រចាំឆ្នាំ ជូនគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានភារកិច្ចជាជំនួយការក្នុងការរៀបចំឯកសារ ប្រមូលឯកសារ និងធ្វើការទំនាក់ទំនងលេខាធិការដ្ឋាន គ.រ.ប.ជ ឬ គ.ខ.ប.ជ ព្រមទាំងបំពេញការងារបច្ចេកទេស តាមការណែនាំរបស់ក្រុមការងារវាយតម្លៃផ្តល់ចំណាត់ថ្នាក់ប្រចាំឆ្នាំ ជូនគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

**ប្រការ ៣ ៖**

លោកជំទាវ ឯកឧត្តម អស់លោក លោកស្រីដែលមានឈ្មោះក្នុងប្រការ១ និងប្រការ៣ ត្រូវអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ, ថ្ងៃទី...១២...ខែ...មិថុនា...ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

**សម្តេចក្រឡាហោម ស ខេង**

**<u>ចម្លងជូន</u>**

-ក្រុមការងារជំនាញអន្តរក្រសួង-ស្ថាប័នទាំង៦
-ខុទ្ទកាល័យសម្តេចក្រឡាហោម
-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
-ប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ
-ដូចប្រការ៣
-ឯកសារ កាលប្បវត្តិ